ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៤០៩ ត្រីមាសទី០១ ឆ្នាំ២០២១

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

២៥-១១-២០២០	-ព្រះរាជក្រម នស/រកម/១១២០/០៣៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី សេវាកម្ម	៩៩៥

២~ព្រះរាជក្រឹត្យ

៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៧ ស្តីពី ការនិយ័តកម្មតម្លើងថ្នាក់ នៅក្រសួងមុខងារសាធារណៈ ដល់មន្ត្រីរាជការ ២ រូប	១០៧៨
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមកម្រិតសញ្ញាបត្រ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ២ រូប	១០៧៩
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ដល់មន្ត្រីរាជការ ៦៦ រូប	១០៨០
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ៥ រូប	១០៨៣
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា អស់លោក និងអ្នកស្រី ចំនួន ៤៥ រូប	១០៨៤
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ២៥ រូប	១០៨៦
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក លោកស្រី និងព្រះសង្ឃ ចំនួន ៥៦ រូប/អង្គ	១០៨៨
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ អស់លោក ចំនួន ១២ រូប	១០៩០
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១២ រូប	១០៩១
៦-២-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០២២១/១២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១០ រូប	១០៩២

II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៣-១២-២០២០ -សេចក្ដីសម្រេចលេខ ២០៨/០០៨/២០២០ កបធ.ច ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ លើ សំណុំរឿងលេខៈ ៤០០/០៤២/២០២០, ៤០១/០៤៣/២០២០, ៤០២/០៤៤/២០២០, ៤០៣/០៤៥/២០២០, ៤០៤/០៤៦/២០២០, ៤០៥/០៤៧/២០២០, ៤០៦/០៤៨/២០២០, ៤០៧/០៤៩/២០២០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ១០៩៣

២៣-១២-២០២០ -សេចក្ដីសម្រេចលេខ ២០៩/០០៩/២០២០ កបធ.ច ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ លើ សំណុំរឿងលេខៈ ៤០៨/០៥០/២០២០, ៤០៩/០៥១/២០២០, ៤១០/០៥២/២០២០, ៤១១/០៥៣/២០២០, ៤១២/០៥៤/២០២០, ៤១៣/០៥៥/២០២០ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ១០៩៧

២៥-១២-២០២០ -សេចក្ដីសម្រេចលេខ ២១០/០១០/២០២០ កបធ.ច ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ លើ សំណុំរឿងលេខៈ ៤១៤/០៥៦/២០២០, ៤១៥/០៥៧/២០២០, ៤១៦/០៥៨/២០២០, ៤១៧/០៥៩/២០២០, ៤១៨/០៦០/២០២០, ៤១៩/០៦១/២០២០, ៤២០/០៦២/២០២០, ៤២១/០៦៣/២០២០, ៤២២/០៦៤/២០២០, ៤២៣/០៦៥/២០២០, ៤២៤/០៦៦/២០២០, ៤២៥/០៦៧/២០២០ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ១១០១

III~រាជរដ្ឋាភិបាល

អនុក្រឹត្យ

៤-២-២០២១ -អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ១១០៦

៤-២-២០២១ -អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ១១១០

៤-២-២០២១ -អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ១១១១

៤-២-២០២១ -អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១១១៣

IV~ការងារបណ្ដាក្រសួង

១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣០-៦-២០២០ -ប្រកាសលេខ ៥៤២ សហវ.ប្រក ស្ដីពី ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ និង ស្តង់ដាសវនកម្មសមិទ្ធកម្ម ១១១៧

២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២៩-៥-២០២០ -ប្រកាសលេខ ២៦១១ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម ១១២០

ព្រះរាជក្រម

នស/រកម/១១២០/០៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

មាត្រា១ .-

អនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅប្រទេសសិង្ហបុរី នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ១០កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២០

នស.រកម.១១២០.០២៤

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន សូរស័ក្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៤ សប្រទ

ថ្ងៃ សុក្រ ៩រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្ដម **ប៉ាន សូរស័ក្ដិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាលើ ពិធីសារដើម្បីអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម។

ក្នុងករណីដែលឯកឧត្ដម **ប៉ាន សូរស័ក្ដិ** មានធុរៈជាយថាហេតុ ឯកឧត្ដមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

៩៥

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

រាជរដ្ឋាភិបាល
Royal Government

N: 68 DFP

Phnom Penh, 2 November 2018

DELEGATION OF FULL POWERS

- Considering the Constitution of the Kingdom of Cambodia,
- Considering the Royal Decree NS/RKT/0918/925 dated 06 September 2018 on the Nomination of the Royal Government of Cambodia,
- Considering the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of Council of Ministers,
- Considering the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce,
- Pursuant to the Proposal of the Minister of Commerce.

THE ROYAL GOVERNMENT

Delegates herewith Full Powers to His Excellency **PAN SORASAK**, Minister of Commerce and ASEAN Economic Minister for Cambodia, to sign, on behalf of the Royal Government of Cambodia, the Protocol to Implement the Tenth Package of Commitments under the ASEAN Framework Agreement on Services.

These Powers include the Power of Delegation.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

95

ពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

រដ្ឋាភិបាលនៃព្រុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (ដែលតទៅនេះហៅកាត់រួមគ្នាថា "បណ្តារដ្ឋសមាជិក" ឬ ហៅដោយឡែកពីគ្នាថា "រដ្ឋសមាជិក")។

ដោយកត់សម្គាល់ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ (ហៅកាត់ថា "កិច្ចព្រមព្រៀង AFAS") ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក ដោយលុបបំបាត់ឱ្យបានច្រើនបំផុតនូវការរឹតត្បិតនានាចំពោះពាណិជ្ជកម្មសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម តាមរយៈការពង្រីកភាពស៊ីជម្រៅនិងវិសាលភាពនៃការធ្វើសេរីភាវូបនីយកម្មឱ្យលើសពីអ្វីដែលបានធ្វើឡើងដោយបណ្តារដ្ឋសមាជិក នៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។

ដោយ បានដំណើរការចរចាចំនួនប្រាំពីរលើក និងបានបញ្ចប់កញ្ចប់សន្យាចំនួនប្រាំបួនដែលបានដាក់បញ្ចូលក្នុងពិធីសារអនុវត្តកញ្ចប់សន្យាដំបូង ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ពិធីសារអនុវត្តកញ្ចប់សន្យាទី២ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ពិធីសារអនុវត្តកញ្ចប់សន្យាទី៣ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០១ ពិធីសារអនុវត្តកញ្ចប់សន្យាទី៤ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៤ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ពិធីសារអនុវត្តកញ្ចប់សន្យាទី៥ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ពិធីសារអនុវត្តកញ្ចប់សន្យាទី៦ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី ពិធីសារអនុវត្តកញ្ចប់សន្យាទី៧ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ នៅចាអាម ប្រទេសថៃ ពិធីសារអនុវត្តកញ្ចប់សន្យាទី៨ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ពិធីសារអនុវត្តកញ្ចប់សន្យាទី៩ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។

ដោយកត់សម្គាល់ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់សមាហរណកម្មវិស័យអាទិភាព រួមជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មវិស័យអាទិភាព ដែលបានចុះហត្ថលេខាដោយប្រមុខដឹកនាំអាស៊ាន នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន(វិសោធនកម្ម)សម្រាប់សមាហរណកម្មវិស័យអាទិភាព ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន និងពិធីសារធ្វើវិសោធនកម្មលើមាត្រា៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន(វិសោធនកម្ម)សម្រាប់សមាហរណកម្មវិស័យអាទិភាព ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន ដោយរួមបញ្ចូលសេវាកម្មតាមផ្លូវអាកាស សេវាកម្មថែទាំសុខភាព សេវាកម្មអាស៊ានតាមប្រព័ន្ធអេឡិចត្រូនិក (សេវាកម្មទូរគមនាគមន៍និងសេវាកម្មព័ត៌មានវិទ្យា) សេវាកម្មទេសចរណ៍ និងសេវាកម្មឡូជីស្ទិក ដោយផ្តល់វិធានការនានា ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅនិងពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងការតភ្ជាប់នានា ដើម្បីសម្រេចបាននូវសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយមានការចូលរួមពីវិស័យឯកជន។

ដោយកត់សម្គាល់ផងដែរ គោលដៅនិងពេលវេលាកំណត់របស់ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបានអនុម័តនៅកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី ដែលផ្តល់នូវការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម តាមរយៈការធ្វើសេរីភាវូបនីយកម្មជាបន្តបន្ទាប់ ក្នុងចំណោមគោលដៅសំខាន់ៗដទៃទៀត ក្នុងផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ដោយអះអាង លើការប្តេជ្ញាបញ្ចប់កញ្ចប់សន្យាទី១០ (ហៅកាត់ថា "កញ្ចប់ទី១០") ដោយបំពេញបានតាមលក្ខខណ្ឌតម្រូវដូចដែលបានឯកភាពនៅកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៤ នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ នៅសៀមរាប ប្រទេសកម្ពុជា។

ដោយមានបំណង អនុវត្តកញ្ចប់ទី១០ តាមពេលវេលាកំណត់ដូចមានចែងនៅក្នុងពិធីសារនេះ។

បានព្រមព្រៀងគ្នាដូចខាងក្រោម៖

១. ឧបសម្ព័ន្ធនានារបស់ពិធីសារនេះត្រូវមានតារាងរួមនៃតារាងសន្យាតាមវិស័យ តារាងសន្យាទូទៅ និងបញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់រដ្ឋសមាជិកនីមួយៗ ដែលត្រូវបង្កើតជាផ្នែកដ៏សំខាន់នៃពិធីសារនេះ។

២. ដោយផ្អែកលើតារាងសន្យានិងបញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់រដ្ឋសមាជិកនីមួយៗ បណ្តារដ្ឋសមាជិកត្រូវផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះដល់គ្នាទៅវិញទៅមក ដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត។

៣. ពិធីសារនេះនិងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ ត្រូវបង្កើតជាផ្នែកដ៏សំខាន់នៃកិច្ចព្រមព្រៀង AFAS ។

៤. រដ្ឋសមាជិកនីមួយៗត្រូវដាក់ជូននូវតារាងសន្យាតាមវិស័យ តារាងសន្យាទូទៅ និងបញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់ខ្លួន នៅពេលចុះហត្ថលេខាលើពិធីសារនេះ។

៥. ពិធីសារនេះនិងការសន្យាទាំងឡាយដូចមានចែងនៅក្នុងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើពិធីសារនេះ។

៦. បណ្តារដ្ឋសមាជិកត្រូវបំពេញនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃពិធីសារនេះនិងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ។ រដ្ឋសមាជិកនីមួយៗត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការអាស៊ាន បន្ទាប់ពីការបញ្ចប់នូវនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃពិធីសារនេះ។

៧. ក្នុងករណីរដ្ឋសមាជិកណាមួយពុំអាចជូនដំណឹងអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ នៃកាលបរិច្ឆេទចុះហត្ថលេខា នោះរាល់សិទ្ធិនិងកាតព្វកិច្ចទាំងឡាយរបស់រដ្ឋសមាជិកនោះ ដែលស្ថិតក្រោមពិធីសារនេះនិងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីកាលបរិច្ឆេទដែលរដ្ឋសមាជិកនោះជូនដំណឹងអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

៨. ចំពោះរដ្ឋសមាជិកណាមួយដែលពុំអាចដាក់ជូននូវការសន្យាពេញលេញរបស់ខ្លួនក្រោមកញ្ចប់ទី១០ នៅថ្ងៃចុះហត្ថលេខាលើពិធីសារនេះ៖

(ក) ការសន្យាពេញលេញដែលត្រូវដាក់ជូនពេលបន្ទាប់ ក៏ប៉ុន្តែមុនពេលចូលជាធរមានរបស់ពិធីសារនេះ និងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ ត្រូវចូលជាធរមានផងដែរក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើពិធីសារនេះ និង

(ខ) ការសន្យាពេញលេញដែលត្រូវដាក់ជូនបន្ទាប់ពីការចូលជាធរមានរបស់ពិធីសារនេះនិងឧបសម្ព័ន្ធនានារបស់ពិធីសារនេះ ត្រូវចូលជាធរមានបន្ទាប់ពីការដាក់ជូនរបស់ខ្លួន។

៩. ថ្វីបើមានចែងក្នុងកថាខណ្ឌ២ ការសន្យាពេញលេញរបស់រដ្ឋសមាជិកណាមួយក្រោមកញ្ចប់ទី១០ ត្រូវបានអនុវត្តតែចំពោះបណ្តារដ្ឋសមាជិកដទៃទៀតដែលបានដាក់ជូននូវការសន្យាពេញលេញរបស់ខ្លួនក្រោមកញ្ចប់ទី១០ តែប៉ុណ្ណោះ លុះត្រាតែរដ្ឋសមាជិកនោះធ្វើការសម្រេចចិត្តផ្ទុយពីនេះ។

១០. សម្រាប់គោលបំណងនៃពិធីសារនេះ រដ្ឋសមាជិកណាមួយត្រូវបានចាត់ទុកថា បានដាក់ជូននូវ *"ការសន្យាពេញលេញ"* នៅពេលដែលខ្លួនបានដាក់ជូននូវការសន្យាទាំងឡាយ ដែលបំពេញបានឬលើសពីលក្ខខណ្ឌតម្រូវ ដែលបានកំណត់នៅកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៤ នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ នៅសៀមរាប ប្រទេសកម្ពុជា។

១១. បណ្តារដ្ឋសមាជិកទាំងឡាយណាដែលមិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវរបស់កញ្ចប់ទី១០ ត្រូវខិតខំប្រឹងប្រែងដាក់ជូននូវការសន្យាពេញលេញរបស់ខ្លួនក្នុងរយៈពេលបីឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ។

១២. ពិធីសារនេះត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជូននូវច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវទៅកាន់រដ្ឋសមាជិកនីមួយៗឱ្យបានឆាប់។ អគ្គលេខាធិការអាស៊ានត្រូវផ្តល់ជូនរដ្ឋសមាជិកនីមួយៗផងដែរនូវសេចក្តីជូនដំណឹងដែលត្រូវបានធ្វើឡើងដោយអនុលោមតាមពិធីសារនេះ។

ជាសក្ខីភាព ហត្ថលេខីខាងក្រោម ដោយទទួលបានសិទ្ធិប្រទានពេញលេញដែលផ្តល់ដោយរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

ធ្វើ នៅប្រទេសសិង្ហបុរី នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងឯកសារច្បាប់ដើមតែមួយគត់ជាភាសាអង់គ្លេស។

តំណាងរដ្ឋានៃគិបាលព្រុយណេ

ERYWAN PEHIN YUSOF

រដ្ឋមន្ត្រីទី២ក្រសួងការបរទេសនិងពាណិជ្ជកម្ម

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

PAN SORASAK

រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី

ENGGARTIASTO LUKITA

រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

KHEMMANI PHOLSENA

រដ្ឋមន្ត្រីឧស្សាហកម្មនិងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី

DARELL LEIKING

រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្មអន្តរជាតិ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

U SOE WIN

រដ្ឋមន្ត្រីសហភាពសម្រាប់ផែនការនិងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

RAMON M. LOPEZ

រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

CHAN CHUN SING

រដ្ឋមន្ត្រីពាណិជ្ជកម្មនិងឧស្សាហកម្ម

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

CHUTIMA BUNYAPRAPHASARA

អនុរដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

TRAN TUAN ANH

រដ្ឋមន្ត្រីឧស្សាហកម្មនិងពាណិជ្ជកម្ម

asean

Note No.: 403/2018

The ASEAN Secretariat presents its compliments to the Permanent Mission of ASEAN Member States and has the honour to transmit herewith the Certified Copy of the Protocol to Implement the Tenth Package of Commitments under the ASEAN Framework Agreement on Services, signed on 11 November 2018 in Singapore.

The ASEAN Secretariat would appreciate it if the Permanent Missions could forward the Certified Copy of the said Protocol to their respective appropriate authority/destination.

The ASEAN Secretariat avails itself of this opportunity to renew to the Permanent Missions the assurances of its highest consideration.

Jakarta, 24 December 2018

ASSOCIATION OF SOUTHEAST ASIAN NATIONS ASEAN SECRETARIAT JAKARTA

Permanent Mission of ASEAN Member States
Jakarta

ASSOCIATION
OF SOUTHEAST
ASIAN NATIONS

The ASEAN Secretariat
70 A Jl. Sisingamangaraja
Jakarta 12110
Indonesia

Phone: (62-21) 726 2991
(62-21) 724 3372
Fax: (62-21) 739 8234
(62-21) 724 3504

public@asean.org
www.asean.org

CERTIFYING STATEMENT

Protocol to Implement the Tenth Package of Commitments under the ASEAN Framework Agreement on Services

I, THE UNDERSIGNED Deputy Secretary-General of ASEAN for Community and Corporate Affairs, hereby certify that the attached text is **a true and complete copy** of the Protocol to Implement the Tenth Package of Commitments under the ASEAN Framework Agreement on Services, signed on 11 November 2018, the original of which has been deposited with the Secretary-General of ASEAN.

Jakarta, 24 December 2018

AKP Mochtan
Deputy Secretary-General of ASEAN
Community and Corporate Affairs
Department
The ASEAN Secretariat

PROTOCOL TO IMPLEMENT
THE TENTH PACKAGE OF COMMITMENTS UNDER
THE ASEAN FRAMEWORK AGREEMENT ON SERVICES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Member States" or singularly as "Member State");

NOTING the ASEAN Framework Agreement on Services signed on 15 December 1995 in Bangkok, Thailand (hereinafter referred to as "AFAS"), which seeks to enhance cooperation in services amongst Member States, to eliminate substantially all restrictions to trade in services amongst Member States and to liberalise trade in services by expanding the depth and scope of liberalisation beyond those undertaken by Member States under the General Agreement on Trade in Services (GATS) of the World Trade Organization (WTO);

HAVING carried out seven rounds of negotiations and concluded nine packages of commitments embodied in the Protocol to Implement the Initial Package of Commitments under the ASEAN Framework Agreement on Services signed on 15 December 1997 in Kuala Lumpur, Malaysia; the Protocol to Implement the Second Package of Commitments under the ASEAN Framework Agreement on Services signed on 16 December 1998 in Ha Noi, Viet Nam; the Protocol to Implement the Third Package of Commitments under the ASEAN Framework Agreement on Services signed on 31

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

December 2001; the Protocol to Implement the Fourth Package of Commitments under the ASEAN Framework Agreement on Services signed on 3 September 2004 in Jakarta, Indonesia; the Protocol to Implement the Fifth Package of Commitments under the ASEAN Framework Agreement on Services signed on 8 December 2006 in Cebu, Philippines; the Protocol to Implement the Sixth Package of Commitments under the ASEAN Framework Agreement on Services signed on 19 November 2007 in Singapore; the Protocol to Implement the Seventh Package of Commitments under the ASEAN Framework Agreement on Services signed on 26 February 2009 in Cha-am, Thailand; the Protocol to implement the Eighth Package of Commitments under the ASEAN Framework Agreement on Services signed on 28 October 2010 in Ha Noi, Viet Nam; and the Protocol to Implement the Ninth Package of Commitments under the ASEAN Framework Agreement on Services signed on 27 November 2015 in Makati City, Philippines;

NOTING the ASEAN Framework Agreement for the Integration of Priority Sectors together with the Roadmaps for the Integration of Priority Sectors signed by the ASEAN Leaders on 29 November 2004 in Vientiane, Lao PDR; the ASEAN Framework (Amendment) Agreement for the Integration of Priority Sectors signed by the ASEAN Economic Ministers on 8 December 2006 in Cebu, Philippines; and the Protocol to Amend Article 3 of the ASEAN Framework (Amendment) Agreement for the Integration of Priority Sectors signed by the ASEAN Economic Ministers on 24 August 2007 in Makati City, Philippines, which include air travel, healthcare, e-ASEAN (telecommunications and IT services), tourism, and logistics services, provide measures to deepen and broaden internal economic integration and linkages, with the participation of the private sector, to realise an ASEAN Economic Community;

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

NOTING ALSO the targets and timelines of the ASEAN Economic Community Blueprint adopted at the 13th ASEAN Summit held on 21 November 2007 in Singapore that, amongst others, provided for the liberalisation of trade in services through consecutive rounds of liberalisation;

AFFIRMING the commitment to finalise the Tenth Package of Commitments (hereinafter referred to as "Tenth Package") meeting the thresholds agreed at the 44th Meeting of the ASEAN Economic Ministers held on 28 August 2012 in Siem Reap, Cambodia; and

DESIRING to implement the Tenth Package by the timelines specified in this Protocol,

HAVE AGREED AS FOLLOWS:

1. The Annexes to this Protocol shall consist of the consolidated schedules of each Member State's Schedule of Specific Commitments, Schedule of Horizontal Commitments, and the List of Most-Favoured-Nation Exemptions, which shall form an integral part of this Protocol.

2. Subject to each Member State's Schedule of Commitments and the List of Most-Favoured-Nation Exemptions, Member States shall accord preferential treatment to one another on a Most-Favoured-Nation basis.

3. This Protocol and its Annexes shall form an integral part of the AFAS.

4. Each Member State shall submit its Schedule of Specific Commitments, Schedule of Horizontal Commitments, and List of Most-Favoured-Nation Exemptions at the time of signing of this Protocol.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

5. This Protocol and the commitments set out in its Annexes shall enter into force ninety (90) days after the date of signature of this Protocol.

6. Member States shall complete their internal procedures for the entry into force of this Protocol and its Annexes. Each Member State shall, upon the completion of its internal procedures for the entry into force of this Protocol, notify the Secretary-General of ASEAN in writing.

7. Where a Member State is unable to notify the completion of its internal procedures within ninety (90) days of the date of signature, the rights and obligations of that Member State under this Protocol and its Annexes shall commence on the date on which the Member State notifies the completion of its internal procedures.

8. For a Member State that is unable to submit its full commitments under the Tenth Package by the time of signing of this Protocol:

(a) full commitments that are submitted thereafter but before the entry into force of this Protocol and its Annexes, shall also enter into force ninety (90) days after the date of signature of this Protocol; and

(b) full commitments that are submitted after the entry into force of this Protocol and its Annexes shall enter into force upon their submission.

9. Notwithstanding paragraph 2, the full commitments of a Member State under the Tenth Package shall only be extended to other Member States that are able to submit their full commitments under the Tenth Package, unless the Member State decides otherwise.

10. For the purpose of this Protocol, a Member State shall be considered to have submitted *"full commitments"* when it has submitted commitments which meet or exceed the

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

thresholds set out at the 44th Meeting of the ASEAN Economic Ministers on 28 August 2012 in Siem Reap, Cambodia.

11. The Member States that have not complied with the Tenth Package threshold shall endeavour to submit their full commitments within three years from the date of entry into force of this Protocol.

12. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Member State. The Secretary-General of ASEAN shall also promptly furnish notifications made pursuant to this Protocol to each Member State.

IN WITNESS WHEREOF, the undersigned, being duly authorised thereto by their respective Governments, have signed the Protocol to Implement the Tenth Package of Commitments under the ASEAN Framework Agreement on Services.

DONE at Singapore, this Eleventh Day of November in the Year Two Thousand and Eighteen in a single original copy in the English Language.

For Brunei Darussalam:

ERYWAN PEHIN YUSOF
Minister of Foreign Affairs and Trade II

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Kingdom of Cambodia:

....

PAN SORASAK
Minister of Commerce

For the Republic of Indonesia:



....

ENGGARTIASTO LUKITA
Minister of Trade

For the Lao People's Democratic Republic:



....

KHEMMANI PHOLSENA
Minister of Industry and Commerce

For Malaysia:

....

DARELL LEIKING

Minister of International Trade and Industry

For the Republic of the Union of Myanmar:

....

U SOE WIN

Union Minister for Planning and Finance

For the Republic of the Philippines:

....

RAMON M. LOPEZ

Secretary of the Department of Trade and Industry

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Republic of Singapore:

CHAN CHUN SING
Minicter for Trade and Industry

For the Kingdom of Thailand:

CHUTIMA BUNYAPRAPHASARA
Deputy Minister of Commerce

For the Socialist Republic of Viet Nam:

TRAN TUAN ANH
Minister of Industry and Trade

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
I. HORIZONTAL COMMITMENTS (ការសន្យាទូទៅ)			
Subsidies ការឧបត្ថម្ភធន		(3), (4). Unbound for subsidies, including for research and development មិនសន្យា ចំពោះការឧបត្ថម្ភធន រួមបញ្ចូលទាំងការស្រាវជ្រាវនិងអភិវឌ្ឍន៍	
Tax measures វិធានការពន្ធ		(1), (2), (3) None with respect to taxes ពុំមានការរឹតត្បិត ពាក់ព័ន្ធនឹងពន្ធ	
Land ដីធ្លី		(3) Non-Cambodian natural and juridical persons may lease but not own land. រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយណាដែលមិនមែនសញ្ជាតិកម្ពុជាអាចជួល ប៉ុន្តែគ្មានសិទ្ធិកាន់កាប់ដីធ្លីឡើយ។	
Acquired rights សិទ្ធិដែលទទួលបាន	The conditions of ownership, management, operation, juridical form and scope of activities as set out in a license or other form of approval establishing or authorising the operation or supply of services by an existing foreign service supplier, will not be made more restrictive than those in existence as of the date of Cambodia's accession to the WTO.		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	លក្ខខណ្ឌនានានៃភាពជាម្ចាស់កម្មសិទ្ធិ ការគ្រប់គ្រង ប្រតិបត្តិការ បែបបទគតិយុត្ត និងវិសាលភាពនៃសកម្មភាពនានា ដូចដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណណាមួយ ឬនៅក្នុងទម្រង់បែបបទនៃការអនុញ្ញាតផ្សេងទៀត ដែលបានបង្កើត ឬបានផ្តល់សិទ្ធិ ក្នុងការធ្វើប្រតិបត្តិការ ឬការផ្គត់ផ្គង់សេវាកម្មនានា ដោយអ្នកផ្គត់ផ្គង់សេវាកម្មបរទេសដែលមានស្រាប់ នោះនឹងមិនមានការរឹតត្បិតបន្ថែមច្រើនជាងអ្វីដែលមានស្រាប់ឡើយ គិតចាប់ពីកាលបរិច្ឆេទ ដែលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។		
Investment incentives ការលើកទឹកចិត្តចំពោះការវិនិយោគ	(3) Investors, seeking incentives under the provisions of the Law on Investment, shall have the obligation to provide adequate and consistent training to Cambodian staff, including for promotion to senior positions. អ្នកវិនិយោគទាំងឡាយ ដែលមានបំណងទទួលបានការលើកទឹកចិត្ត ក្រោមលក្ខខណ្ឌនៃច្បាប់វិនិយោគ ត្រូវមានកាតព្វកិច្ចក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ និងសមស្របដល់បុគ្គលិកកម្ពុជា រួមបញ្ចូលទាំងការដំឡើងដំណែងក្នុងតួនាទីជាន់ខ្ពស់ដល់បុគ្គលិកកម្ពុជាផងដែរ ។	(3) None ពុំមានការរឹតត្បិត	

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
Presence of natural persons វត្តមាននៃរូបវន្តបុគ្គល	(4) Unbound except for measures concerning the entry and temporary stay of a natural person who falls in one of the following categories: មិនសន្យា លើកលែងតែវិធានការទាំងឡាយ ដែលពាក់ព័ន្ធនឹងការចូលមក និងការស្នាក់នៅបណ្តោះអាសន្ន របស់រូបវន្តបុគ្គលណាម្នាក់ ដែលបានចាត់ចូលក្នុងប្រភេទដូចខាងក្រោម៖ <u>Business visitors</u> A natural person who: - enters Cambodia for the purposes of participating in business meetings, establishing business contacts including negotiations for the sale of services and/or other similar activities; - stays in Cambodia without receiving income from within Cambodian sources; - does not engage in making direct sales to the general public or supplying services. Entry visa for business visitors shall be valid for a period of 90 days for an initial stay of 30 days, which may be extended.	(4) Unbound, except for measures affecting the categories referred to under market access. មិនសន្យា លើកលែងចំពោះវិធានការទាំងឡាយដែលពាក់ព័ន្ធនឹងប្រភេទនានាដែលមានបញ្ជាក់នៅក្នុងផ្នែកការបើកទីផ្សារ។	

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	<u>អ្នកទស្សនកិច្ចធុរកិច្ច</u> សំដៅលើរូបវន្តបុគ្គលដែល៖ • ចូលមកក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីចូលរួមកិច្ចប្រជុំធុរកិច្ច ឬបង្កើតទំនាក់ទំនងធុរកិច្ចរួមមាន ការចរចាសម្រាប់ការលក់សេវាកម្ម និង/ឬសកម្មភាពនានាដែលប្រហាក់ប្រហែល • ស្នាក់នៅក្នុងប្រទេសកម្ពុជា ដោយពុំមានទទួលបានចំណូលពីប្រភពនានារបស់កម្ពុជា • ពុំមានជាប់ទាក់ទងនឹងការលក់ដោយផ្ទាល់ទៅដល់សាធារណជនទូទៅ ឬការផ្គត់ផ្គង់សេវាកម្មណាមួយ។ ទិដ្ឋាការចូលមកកម្ពុជាសម្រាប់អ្នកទស្សនកិច្ចធុរកិច្ចមានសុពលភាពចំនួន ៩០ថ្ងៃ ដោយការស្នាក់នៅដំបូងមានរយៈពេល ៣០ថ្ងៃ ដែលអាចពន្យារសុពលភាពបាន។		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	<u>Persons responsible for setting up of a commercial establishment:</u> Persons working in an executive or managerial position, receiving remuneration from an entity as defined below, who are responsible for the setting up, in Cambodia, of a commercial presence of a service provider of a Member, that will support employment of persons described in a, b, and c below. The subject persons are not subject to a maximum duration of stay. <u>បុគ្គលដែលមានតួនាទីរៀបចំបង្កើតពាណិជ្ជកម្ម</u> សំដៅលើបុគ្គលដែលធ្វើការនៅក្នុងថ្នាក់នាយកប្រតិបត្តិ ឬថ្នាក់គ្រប់គ្រង ដែលទទួលបានលាភការពីអង្គភាពណាមួយ ដូចដែលបានកំណត់ខាងក្រោម ហើយជាបុគ្គលដែលមានតួនាទីរៀបចំបង្កើតវត្តមានពាណិជ្ជកម្មមួយ របស់អ្នកផ្គត់ផ្គង់សេវាកម្មនៃប្រទេសសមាជិកណាមួយ នៅក្នុងប្រទេសកម្ពុជា ដែលនឹងគាំទ្រដល់ការងាររបស់បុគ្គលដូចបានពណ៌នាក្នុងចំណុច a, b, និង c ខាងក្រោម។ បុគ្គលស្ថិតក្នុងប្រភេទនេះ មិនត្រូវបានកំណត់អំពីរយៈពេលអតិបរមានៃការស្នាក់នៅឡើយ។		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	<u>Intra-Corporate Transferees</u> Natural persons who have been employed by a juridical person of another member for a period of not less than 1 year and who seek temporary entry to provide services through a branch, subsidiary and affiliate in Cambodia and who are: a) <u>Executives</u>: without requiring compliance with labour market tests, persons within an organisation who primarily direct the management of the organisation, exercise wide latitude in decision-making, and receive only general supervision or direction from higher-level executives, the board of directors, or shareholders of thebusiness. Executives would not directly perform tasks related to the actual supply of a service or services of the organisation. b) <u>Managers</u>: without requiring compliance with labour market tests, natural persons employed by a juridical entity and who possess knowledge at an advanced level of expertise or proprietary knowledge of a juridical entity product, service,		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	research, equipment, techniques, or management, and who primarily direct the organisation or a department of the organisation; supervise and control the work of other supervisory, professional or managerial employees; have the authority to hire and fire or recommend hiring, firing or other personnel actions; and exercise discretionary authority over day-to-day operations. They do not include first-line supervisors, unless the employees supervised are professionals, nor do they include employees who primarily perform tasks necessary for the supply of the service. c) Specialists: Natural persons, within an organisation who possess knowledge at an advanced level of continued expertise and who possess proprietary knowledge of the organisation's services, research equipment, techniques, or management. Temporary residency and work permit is required for the natural persons in the categories defined under intra-corporate transferees. Such permits are issued for two years and may be renewed annually up to maximum of total five years.		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: ម៉ូតនៃការផ្គត់ផ្គង់៖	1) Cross-border supply ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន	2) Consumption abroad ២) ការប្រើប្រាស់នៅបរទេស	3) Commercial presence ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	<u>បុគ្គលដែលត្រូវផ្លាស់ប្តូរក្នុងសាជីវកម្មតែមួយ</u> សំដៅលើ រូបវន្តបុគ្គលដែលបម្រើការងារឱ្យនីតិបុគ្គលណាមួយ នៃប្រទេសសមាជិកផ្សេងទៀតក្នុងរយៈពេលមិនតិចជាង ០១ ឆ្នាំ ហើយជាបុគ្គលដែលមានបំណងចូលមកជាបណ្តោះអាសន្ន ដើម្បីផ្តល់សេវាកម្មតាមរយៈ សាខាតំណាង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបុគ្គលនោះគឺជា៖ a) <u>នាយកប្រតិបត្តិ:</u> ដោយពុំមានការតម្រូវឱ្យអនុលោមនឹងការធ្វើតេស្តទីផ្សារពលកម្ម ជាបុគ្គលក្នុងអង្គភាពមួយ ដែលមានភារកិច្ចចម្បងដឹកនាំការគ្រប់គ្រងអង្គភាព ដែលអនុវត្តសេរីភាពនៃការសម្រេចចិត្តទូលំទូលាយ និងទទួលការគ្រប់គ្រងជាទូទៅ ឬទិសដៅពីនាយកប្រតិបត្តិជាន់ខ្ពស់ ក្រុមប្រឹក្សាភិបាល ឬម្ចាស់ភាគហ៊ុនពាណិជ្ជកម្មតែប៉ុណ្ណោះ។ នាយកប្រតិបត្តិមិនបំពេញការងារដោយផ្ទាល់ទាក់ទងនឹងការផ្តល់សេវាកម្មមួយ ឬសេវាកម្មច្រើនរបស់អង្គភាពឡើយ។		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	៦) អ្នកគ្រប់គ្រង: ដោយពុំមានការតម្រូវឱ្យអនុលោមនឹងការធ្វើតេស្តទីផ្សារពលកម្ម ជារូបវន្តបុគ្គលដែលបម្រើការងារឱ្យនីតិបុគ្គលមួយ ព្រមទាំងជាអ្នកដែលមានចំណេះដឹងកម្រិតខ្ពស់លើជំនាញ ឬមានចំណេះដឹងពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈនៃផលិតផលសេវាកម្ម ការស្រាវជ្រាវ គ្រឿងបរិក្ខារបច្ចេកទេស ឬការគ្រប់គ្រងរបស់នីតិបុគ្គល និងជាអ្នកដែលដឹកនាំអង្គភាពឬផ្នែកណាមួយនៃអង្គភាព គ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការរបស់ប្រធានផ្នែកផ្សេងៗ បុគ្គលិកជំនាញ ឬបុគ្គលិកផ្នែកគ្រប់គ្រងផ្សេងទៀត មានអំណាចក្នុងការជួល និងការបញ្ឈប់ការងារ ឬផ្តល់ជាអនុសាសន៍ចំពោះការជួល ការបញ្ឈប់ការងារ ឬចំណាត់ការបុគ្គលិកផ្សេងៗ និងអនុវត្តនូវអំណាចឆន្ទានុសិទ្ធិចំពោះប្រតិបត្តិការនានាប្រចាំថ្ងៃ។ អ្នកគ្រប់គ្រងមិនរាប់បញ្ចូលឋានៈប្រធានក្រុមឡើយ លុះត្រាតែបុគ្គលិកដែលស្ថិតក្រោមបង្គាប់ជាអ្នកមានជំនាញវិជ្ជាជីវៈ ហើយក៏មិនរាប់បញ្ចូលបុគ្គលិកដែលជាទូទៅបំពេញកិច្ចការចាំបាច់នានា សម្រាប់ការផ្គត់ផ្គង់សេវាកម្មផងដែរ។		

CAMBODIA– SCHEDULE OF COMMITMENTS
តារាងសន្យាតាមវិស័យរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Modes of Supply: 1) Cross-border supply 2) Consumption abroad 3) Commercial presence
ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម

Sector or Subsector វិស័យ/អនុវិស័យ	Limitation on Market Access ការរឹតត្បិតលើការបើកទីផ្សារ	Limitation on National Treatment ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ	Additional Commitments ការសន្យាបន្ថែម
	c) <u>អ្នកឯកទេស:</u> សំដៅលើរូបវន្តបុគ្គលនៅក្នុងអង្គភាពមួយ ដែលមានចំណេះដឹងក្នុងកម្រិតឯកទេសជាន់ខ្ពស់ ហើយជាអ្នកមានចំណេះដឹងពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈនៃសេវាកម្មបរិក្ខារស្រាវជ្រាវ បច្ចេកទេស ឬការគ្រប់គ្រង។ រូបវន្តបុគ្គលដែលត្រូវបានចាត់ចូលក្នុងប្រភេទបុគ្គលដែលត្រូវផ្លាស់ប្តូរក្នុងសាជីវកម្មតែមួយ តម្រូវឱ្យមានទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណការងារ។ ការអនុញ្ញាតទាំងនេះមានសុពលភាពរយៈពេលពីរឆ្នាំ ហើយអាចធ្វើឡើងវិញជារៀងរាល់ឆ្នាំ ហួតសរុបរយៈពេលជាអតិបរមាប្រាំឆ្នាំ។		

CAMBODIA– – LIST OF MFN EXEMPTIONS

បញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services

សម្រាប់កញ្ចប់ទី១០នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Sector or sub sector វិស័យ ឬអនុវិស័យ	Description of measure indicating its inconsistency with Article II ការពិពណ៌នាអំពីវិធានការដែលបង្ហាញពីអសង្គតិភាពនឹងមាត្រា II	Countries to which the measure applies ប្រទេសដែលវិធានការនោះអនុវត្តចំពោះ	Intended duration រយៈពេលក្នុងការរក្សាទុក	Conditions creating the need for the exemption ស្ថានភាពដែលបង្កឱ្យមានតម្រូវការចំពោះការលើកលែងនោះ
Audiovisual services សេវាកម្មសោតទស្សន៍				
Production and distribution of television programmes and cinematographic works ការផលិតនិងការចែកចាយកម្មវិធីទូរទស្សន៍ និងស្នាដៃភាពយន្ត	Measures based upon co production agreements of audiovisual works, which confer National Treatment to audiovisual works covered by such agreements. វិធានការផ្អែកលើកិច្ចព្រមព្រៀងនានាអំពីសហផលិតកម្មនៃស្នាដៃសោតទស្សន៍ ដែលផ្តល់ប្រព្រឹត្តិកម្មជាតិចំពោះស្នាដៃសោតទស្សន៍ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងទាំងនេះ។	Countries with which such bilateral or plurilateral agreements are in force, now or in the future ប្រទេសដែលកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីបែបនេះមានជាធរមាន មិនថាក្នុងពេលបច្ចុប្បន្ន ឬអនាគត។	Indefinite មិនកំណត់	The aim of these agreements is to promote cultural links between the countries concerned គោលបំណងនៃកិច្ចព្រមព្រៀងទាំងនេះគឺដើម្បីលើកកម្ពស់ទំនាក់ទំនងវប្បធម៌រវាងប្រទេសពាក់ព័ន្ធ
Production and distribution of television programmes and cinematographic works ការផលិតនិងការចែកចាយកម្មវិធីទូរទស្សន៍ និងស្នាដៃភាពយន្ត	Measures granting the benefit of support programmes (such as "Fonds d'aide a la production de l"agence intergouvernmental de la Francophonie") to audiovisual works, and suppliers of such works meeting origin criteria. វិធានការនានាដែលផ្តល់នូវអត្ថប្រយោជន៍នៃកម្មវិធីគាំទ្រនានា (ដូចជា "Fonds d'aide a la production de l"agence intergouvernmental de la Francophonie") ដល់ស្នាដៃសោតទស្សន៍ និងអ្នកផ្គត់ផ្គង់ស្នាដៃបែបនេះដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យដើមកំណើត។	Countries with which bilateral and plurilateral agreements have been signed in the area of cultural cooperation. ប្រទេសដែលកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីបែបនេះត្រូវបានចុះហត្ថលេខាក្នុងវិស័យកិច្ចសហប្រតិបត្តិការវប្បធម៌។	Indefinite មិនកំណត់	These programmes aim at preserving and promoting the cultural identity of countries with which Cambodia has a long-standing cultural links កម្មវិធីទាំងនេះមានគោលបំណងថែរក្សានិងលើកកម្ពស់អត្តសញ្ញាណវប្បធម៌របស់ប្រទេសទាំងឡាយដែលកម្ពុជាមានទំនាក់ទំនងវប្បធម៌ជាមួយតាំងពីយូរមកហើយ

CAMBODIA– – LIST OF MFN EXEMPTIONS
បញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Sector or sub sector វិស័យ ឬអនុវិស័យ	Description of measure indicating its inconsistency with Article II ការពិពណ៌នាអំពីវិធានការដែលបង្ហាញពីអសង្គតិភាពនឹងមាត្រា II	Countries to which the measure applies ប្រទេសដែលវិធានការនោះអនុវត្តចំពោះ	Intended duration រយៈពេលក្នុងការរក្សាទុក	Conditions creating the need for the exemption ស្ថានភាពដែលបង្កឱ្យមានតម្រូវការចំពោះការលើកលែងនោះ
Production and distribution of audiovisual works through broadcasting transmission to the public ការផលិតនិងការចែកចាយស្នាដៃសោតទស្សន៍ តាមរយៈការបញ្ជូនការផ្សព្វផ្សាយទៅកាន់សាធារណៈ	Measures which extend National Treatment to audiovisual works which meet certain origin criteria regarding access to broadcasting transmission. វិធានការដែលផ្តល់ប្រព្រឹត្តិកម្មជាតិដល់ស្នាដៃសោតទស្សន៍ ដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យដើមកំណើតជាក់លាក់ ពាក់ព័ន្ធនឹងការចូលទៅកាន់ការបញ្ជូនការផ្សព្វផ្សាយ។	Countries with which bilateral or plurilateral agreements concluded in the area of cultural cooperation. ប្រទេសដែលកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីត្រូវបានបញ្ចប់រួចរាល់នៅក្នុងវិស័យកិច្ចសហប្រតិបត្តិការវប្បធម៌។	Indefinite មិនកំណត់	These measures aim, within the sector, to promote cultural values both within Cambodia, and with other countries, including in the region នៅក្នុងវិស័យនេះ វិធានការទាំងនេះមានគោលបំណងលើកកម្ពស់តម្លៃវប្បធម៌ទាំងនៅក្នុងប្រទេសកម្ពុជានិងជាមួយប្រទេសដទៃទៀត រួមទាំងនៅក្នុងតំបន់ផងដែរ
Land transport ការដឹកជញ្ជូនផ្លូវគោក	Facilitation of transport and transit transport agreements. កិច្ចព្រមព្រៀងសម្របសម្រួលដល់ការដឹកជញ្ជូន និងការដឹកជញ្ជូនឆ្លងកាត់	Existing and future bilateral or plurilateral agreements កិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលមានស្រាប់ ឬនឹងមាននាពេលអនាគត	Indefinite មិនកំណត់	The need to promote tourism and trade in transport services especially among the neighbouring countries. តម្រូវការដើម្បីលើកកម្ពស់វិស័យទេសចរណ៍ និងពាណិជ្ជកម្មលើសេវាកម្មដឹកជញ្ជូន ជាពិសេសក្នុងចំណោមប្រទេសជិតខាង

CAMBODIA– – LIST OF MFN EXEMPTIONS
បញ្ជីនៃការលើកលែងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់កម្ពុជា

For the 10th Package of Commitments under ASEAN Framework Agreement on Services
សម្រាប់កញ្ចប់ទី១០ នៃការសន្យាក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

Sector or sub sector វិស័យ ឬអនុវិស័យ	Description of measure indicating its inconsistency with Article II ការពិពណ៌នាអំពីវិធានការដែលបង្ហាញពីអសង្គតិភាពនឹងមាត្រា II	Countries to which the measure applies ប្រទេសដែលវិធានការនោះអនុវត្តចំពោះ	Intended duration រយៈពេលក្នុងការរក្សាទុក	Conditions creating the need for the exemption ស្ថានភាពដែលបង្កឱ្យមានតម្រូវការចំពោះការលើកលែងនោះ
Internal waterways ការដឹកជញ្ជូនតាមផ្លូវទឹកក្នុងស្រុក	Establishes procedures, charges, and specific regulations applicable for ships of countries concerned operating in Mekong river basin បង្កើតនីតិវិធី ការយកថ្លៃ និងបទប្បញ្ញត្តិជាក់លាក់ដែលអាចអនុវត្តបានចំពោះនាវារបស់ប្រទេសដែលពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការនៅក្នុងអាងទន្លេមេគង្គ	Existing and future bilateral or plurilateral agreements កិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលមានស្រាប់ ឬនឹងមាននាពេលអនាគត	Indefinite មិនកំណត់	Ensure and facilitate navigation in the Mekong river. ដើម្បីធានា និងសម្របសម្រួលដល់ទិសដៅនាវាចរណ៍ក្នុងទន្លេមេគង្គ
